ConnectorCare Health Plans

MASSACHUSETTS HEALTH CONNECTOR

តម្លៃសមរម្យ និងគុណភាពខ្ពស់ពី Health Connector

គម្រោង ConnectorCare មានបុព្វលាភប្រចាំខែទាប ឬត្រឹម $0 ថ្លៃចំណាយចេញពីហោប៉ៅទាប និងគ្មានប្រាក់ចំណាយត្រូវបង់មុនទេ។



តើការធានារ៉ាប់រងប្រភេទណាដែលអ្នកទទួលបានជាមួយ ConnectorCare?

គម្រោង ConnectorCare ផ្តល់ជូនការធានារ៉ាប់រងដ៏អស្ចារ្យជាមួយនឹងអត្ថប្រយោជន៍សំខាន់ៗដូចជាការទៅជួបវេជ្ជបណ្ឌិត ឱសថតាមវេជ្ជបញ្ជា និងការថែទាំសង្គ្រោះបន្ទាន់។ **គម្រោង ConnectorCare មានបុព្វលាភប្រចាំខែទាប ការបង់ប្រាក់រួមទាប និងគ្មានប្រាក់ចំណាយត្រូវបង់មុនទេ។** លើសពីនេះ អ្នកប្រហែលជាអាចបើកឱសថតាមវេជ្ជបញ្ជាមួយចំនួន **ដោយមិនគិតថ្លៃ** សម្រាប់ស្ថានភាពសុខភាពរ៉ាំរ៉ៃ ដូចជាជំងឺហឺត ជំងឺសរសៃឈាមបេះដូង (ប្រភេទជំងឺបេះដូង) ជំងឺទឹកនោមផ្អែម និងជំងឺលើសឈាម (សម្ពាធឈាមខ្ពស់)។

មានប្រភេទគម្រោង ConnectorCare ផ្សេងៗគ្នាដែលផ្អែកលើប្រាក់ចំណូលរបស់អ្នក។ គម្រោងទាំងអស់ដែលផ្តល់ជូនសម្រាប់ប្រភេទគម្រោងនីមួយៗនឹងមានអត្ថប្រយោជន៍ និងការបង់ប្រាក់រួមដូចគ្នាសម្រាប់សេវាកម្មដែលបានធានារ៉ាប់រង។ អ្នកអាចមើលឃើញការបង់ប្រាក់រួមសម្រាប់សេវាផ្សេងនៅក្នុងតារាងនៅទំព័របន្ទាប់។ អ្នកក៏អាចមើលឃើញឧទាហរណ៍អំពីបុព្វលាភប្រចាំខែសម្រាប់ប្រភេទគម្រោងនីមួយៗផងដែរ។

គម្រោង ConnectorCare ត្រូវបានផ្តល់ជូនដោយក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេនៅក្នុងរដ្ឋ។ គម្រោងរបស់ក្រុមហ៊ុនធានារ៉ាប់រងនីមួយៗអាចមានវេជ្ជបណ្ឌិត ឬមន្ទីរពេទ្យផ្សេងៗគ្នានៅក្នុងបណ្តាញអ្នកផ្តល់សេវារបស់ពួកគេ។ មុនពេលអ្នកចុះឈ្មោះ សូមប្រើឧបករណ៍អនឡាញរបស់យើង ដើម្បីមើលថាតើអ្នកផ្តល់សេវាដែលអ្នកចង់បាន និងឱសថតាមវេជ្ជបញ្ជាដែលអ្នកត្រូវការត្រូវបានធានារ៉ាប់រងនៅក្នុងបណ្តាញរបស់គម្រោងដែរឬទេ។ អ្នកអាចស្វែងរកឧបករណ៍ទាំងនេះនៅ៖ **PlanFinder.MAhealthconnector.org**។

តើអ្នកណាអាចមានលក្ខណៈគ្រប់គ្រាន់សម្រាប់គម្រោង ConnectorCare?

អ្នកដែលមានប្រាក់ចំណូលក្នុងគ្រួសារចន្លោះពី 100% ទៅ 400% នៃកម្រិតភាពក្រីក្រសហព័ន្ធ (Federal Poverty Level, FPL) អាចមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ ConnectorCare.. ប្រសិនបើប្រាក់ចំណូលរបស់អ្នកខ្ពស់ជាង 400% នៃ FPL (**តារាងទី 1**) អ្នកនឹងមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់គម្រោង ConnectorCare ទេ។ ដើម្បីមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់គម្រោង ConnectorCare អ្នកនឹងត្រូវបំពេញតាមតម្រូវការដូចខាងក្រោម៖

- ☑ រស់នៅរដ្ឋ Massachusetts
- ☑ ជាពលរដ្ឋអាមេរិក មានសញ្ជាតិ ឬជាជនអន្តោប្រវេសន៍បច្ចុប្បន្នស្របច្បាប់នៅក្នុងសហរដ្ឋអាមេរិក
- ☒ មិនមានសិទ្ធិចូលប្រើប្រាស់ការធានារ៉ាប់រងសុខភាពគ្រប់ជ្រុងជ្រោយដែលមានតម្លៃសមរម្យរបស់និយោជក (រួមទាំងគម្រោងដែលអ្នកត្រូវបានផ្តល់ជូន ប៉ុន្តែមិនបានចុះឈ្មោះ)
- ☒ មិននៅក្នុងគុក ឬពន្ធនាគារ
- ☒ មិនមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ Medicare, MassHealth (Medicaid) ឬ កម្មវិធីធានារ៉ាប់រងសុខភាពសាធារណៈផ្សេងទៀត

តារាងទី 1. គ្រួសារ និង 400% FPL

ទំហំគ្រួសារ	400% FPL
1	$63,840
2	$86,560
3	$109,280
4	$132,000

សម្រាប់ការបន្ថែមមនុស្សម្នាក់ទៀតនៅក្នុងគ្រួសារ សូមបន្ថែម $22,720

តារាងទី 2. ប្រភេទគម្រោង និង FPL

ប្រភេទគម្រោង	ដែនចន្លោះ FPL
ប្រភេទគម្រោង 2A	100-150% FPL
ប្រភេទគម្រោង 2B	150.1-200% FPL
ប្រភេទគម្រោង 3A	200.1-250% FPL
ប្រភេទគម្រោង 3B	250.1-300% FPL
ប្រភេទគម្រោង 3C	300.1-400% FPL

មានសំណួរឬ?

ចូលទៅកាន់ **MAhealthconnector.org** ឬទូរសព្ទទៅ **1-877-MA-ENROLL** (1-877-623-6765) ឬ TTY៖ 711។

តើគម្រោង ConnectorCare មួយណាដែលអ្នកអាចមានលក្ខណៈគ្រប់គ្រាន់?

ថ្លៃចំណាយនៃគម្រោង ConnectorCare មានភាពខុសគ្នាអាស្រ័យលើក្រុមហ៊ុនធានារ៉ាប់រងសុខភាព និងប្រភេទគម្រោង។ ប្រភេទគម្រោងដែលអ្នកមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានគឺផ្អែកលើប្រាក់ចំណូលរបស់អ្នក។ អ្នកអាចរកឃើញដែនចន្លោះ FPL សម្រាប់ប្រភេទគម្រោង ConnectorCare **ក្នុងតារាងទី 2** នៅផ្នែកម្ខាងទៀត។

មានជម្រើសនៃការធានារ៉ាប់រងផ្សេងៗគ្នាសម្រាប់ជនជាតិដើមអាមេរិក និងជនជាតិដើមអាឡាស្កា។ ជនជាតិដើមអាមេរិក និងជនជាតិដើមអាឡាស្កាអាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីទទួលបានប្រាក់ចំណាយចេញពីហោប៉ៅទាបតាមរយៈគម្រោង ConnectorCare និងគម្រោង Health Connector ផ្សេងទៀត។ សូមចូលទៅកាន់ MAhealthconnector.org ដើម្បីស្វែងយល់បន្ថែម។

តារាងទី 3. ថ្លៃបុព្វលាភគម្រោង ConnectorCare ប្រចាំខែតម្លៃទាបបំផុតសម្រាប់មនុស្សម្នាក់ៗក្នុងឆ្នាំ 2027

ប្រភេទគម្រោង	2A	2B	3A	3B	3C
ថ្លៃចំណាយគម្រោងទាបបំផុត	$0	$55	$107	$158	$42

តារាងទី 4. អត្ថប្រយោជន៍ និងការបង់ប្រាក់រួមក្នុងគម្រោង ConnectorCare

ប្រភេទគម្រោង		ប្រភេទគម្រោង 2A និង 2B	ប្រភេទគម្រោង 3A, 3B និង 3C
ថ្លៃចំណាយវេជ្ជសាស្ត្រចេញពីហោប៉ៅអតិបរមា (បុគ្គល/គ្រួសារ)		$750/$1,500	$1,500/$3,000
ថ្លៃចំណាយឱសថតាមវេជ្ជបញ្ជាចេញពីហោប៉ៅអតិបរមា (បុគ្គល/គ្រួសារ)		$500/$1,000	$750/$1,500
ការថែទាំបង្ការ/ឆ្លៈពិនិត្យ/ចាក់ថ្នាំបង្ការ		$0	$0
ការទៅជួបថែទាំបឋមដើម្បីព្យាបាលរបួស ឬជំងឺ (លើកលែង ការថែទាំទារកទើបកើត បង្ការ និងថតកាំរស្មីអ៊ិច)		$5	$10
ការទៅជួបនៅការិយាល័យឯកទេស		$20	$25
សេវាសុខភាពផ្លូវចិត្ត/អាកប្បកិរិយា និងសេវាអ្នកជំងឺក្រៅស្តីពីរបត្តិប្រើប្រាស់សារធាតុញៀន		$5	$10
ការព្យាបាលស្តារនីតិសម្បទានិយាយស្តីឡើងវិញ		$10	$20
ការព្យាបាលដោយធ្វើកិច្ចការដើម្បីស្តារនីតិសម្បទា និងការព្យាបាលដោយចលនារាងកាយដើម្បីស្តារនីតិសម្បទា		$10	$20
សេវាបន្ទប់សង្គ្រោះបន្ទាន់		$50	$100
ការថែទាំបន្ទាន់		$20	$25
ការវះកាត់អ្នកជំងឺក្រៅ		$50	$125
សេវាមន្ទីរពេទ្យអ្នកជំងឺស្នាក់ព្យាបាលទាំងអស់ (រួមទាំងសេវាសុខភាពផ្លូវចិត្ត/អាកប្បកិរិយា និងរបត្តិប្រើប្រាស់សារធាតុញៀន)		$50	$250
ការថតរូបដែលមានថ្លៃចំណាយខ្ពស់ (ការស្កេន CT/PET, MRI ។ល។)		$30	$60
សេវាបន្ទប់ពិសោធន៍សម្រាប់អ្នកជំងឺក្រៅ និងសេវាប្រកបដោយវិជ្ជាជីវៈ		$10	$15
ការថតកាំរស្មីអ៊ិច និងធ្វើរោគវិនិច្ឆ័យ		$10	$15
មន្ទីរថែទាំសុខភាពប្រកបដោយជំនាញ		$50	$250
ឱសថតាមតាមវេជ្ជបញ្ជានៅកន្លែងលក់រាយ៖	ទូទៅ	$10	$15
	ឱសថមានម៉ាកយីហោដែលពេញចិត្ត	$20	$30
	ឱសថមានម៉ាកយីហោមិនពេញចិត្ត	$40	$50
	ឱសថឯកទេសដែលមានថ្លៃចំណាយខ្ពស់	$40	$50

ទទួលបានជំនួយដោយផ្ទាល់ឥតគិតថ្លៃ។ មានកន្លែងជាច្រើនដែលអ្នកអាចទទួលបានជំនួយដោយផ្ទាល់ឥតគិតថ្លៃដើម្បីដាក់ពាក្យ និងចុះឈ្មោះ។ អ្នកគ្រប់គ្នាអាចទទួលបានជំនួយ ទោះបីជាអ្នកមិនមានប្រាក់ចំណូលទាបក៏ដោយ។ សម្រាប់បញ្ជីកន្លែងដើម្បីទទួលបានជំនួយដែលនៅជិតអ្នក សូមចូលទៅកាន់ **MAhealthconnector.org/here-to-help**

ATTENTION: If you speak another language, there are free language assistance services available to you. Call 1-877-623-6765 (TTY: 711).

MASSACHUSETTS · Harvard Pilgrim Health Care · TUFTS Health Plan · fallonhealth · Health New England (Where you matter.) · United Healthcare · Mass General Brigham Health Plan · WellSense HEALTH PLAN

Massachusetts Health Connector អនុលោមតាមច្បាប់សិទ្ធិស៊ីវិលរបស់សហព័ន្ធ និងរដ្ឋជាធរមាន ហើយមិនរើសអើងដោយផ្អែកលើជាតិសាសន៍ ពណ៌សម្បុរ សញ្ជាតិដើម ឬពូជពង្ស កេទ អាយុ ពិការភាព ស្ថានភាពឬលក្ខខណ្ឌសុខភាព គុណភាពជីវិត ឬជំនឿសាសនាឡើយ។